ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងព័ត៌មាន

MINISTRY OF INFORMATION

លេខ...១៧៩៥...ព.ម

ថ្ងៃពុធ ១៣កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី...២៨...ខែមេសា...ឆ្នាំ...២០២១

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបន្តសុពលភាពលិខិតអនុញ្ញាតធ្វើដំណើរ ក្នុងអំឡុងពេលអនុវត្តវិធានការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល

យោង៖ -សេចក្តីសម្រេចលេខ ៥៤ សសរ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាលកម្ពុជា។

-សេចក្តីសម្រេចលេខ ៥០ សសរ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាលកម្ពុជា។

ក្រសួងព័ត៌មានសូមជម្រាបជូនដំណឹងដល់ម្ចាស់អង្គភាពប្រព័ន្ធផ្សព្វផ្សាយ និងមន្ត្រីព័ត៌មានទាំងអស់ មេត្តាជ្រាបថា រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចបន្តការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល សម្រាប់រយៈពេល ៧ (ប្រាំពីរ) ថ្ងៃបន្តទៀត រហូតដល់ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២១ ដូច្នេះ អង្គភាពប្រព័ន្ធផ្សព្វផ្សាយ និងមន្ត្រីព័ត៌មានទាំងអស់ដែលបានទទួលលិខិតអនុញ្ញាតធ្វើដំណើរពីក្រសួងព័ត៌មាន អាចបន្តសុពលភាព និងប្រើប្រាស់លិខិតអនុញ្ញាតធ្វើដំណើររហូតដល់ការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាលបានបិទបញ្ចប់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ ម្ចាស់អង្គភាពប្រព័ន្ធផ្សព្វផ្សាយ មន្ត្រីព័ត៌មាន និងអង្គភាពជំនាញពាក់ព័ន្ធមេត្តាជ្រាប និងចូលរួមអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

រដ្ឋមន្ត្រី

ខៀវ កាញារីទ្ធ

ចម្លងជូន៖

- ក្រសួងមហាផ្ទៃ
- ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ
- ស្នងការដ្ឋាននគរបាលខេត្តកណ្តាល
- អង្គភាពជំនាញពាក់ព័ន្ធ

"ដើម្បីជូនជ្រាប"

- ឯកសារ - កាលប្បវត្តិ